# សវនកម្មសង្គមនៅ NREGS

Binoy Acharya

ការអនុម័តច្បាប់ស្តីអំពីការធានាផ្តល់ការងារសម្រាប់តំបន់ជនបទរបស់ជាតិ (NREGA) នៅឆ្នាំ ២០០៥ គឺជាកិច្ចខិតខំប្រឹងប្រែងត្រួសត្រាយមួយយ៉ាងសំខាន់ ដើម្បីជួយបង្កើនការងារសម្រាប់អ្នកស្រុកក្រីក្រនៅតាមតំបន់ជនបទ។ ច្បាប់នេះធានាឱ្យមានការងារធ្វើឱ្យបាន ១០០ ថ្ងៃក្នុងមួយឆ្នាំដល់គ្រួសារតំបន់ជនបទណាដែលមានសមាជិកពេញវ័យរបស់ខ្លួនចង់ធ្វើការងារដោយប្រើកម្លាំងពលកម្មដែលគ្មានជំនាញ។ បច្ចុប្បន្ននេះវាគ្របដណ្តប់នៅគ្រប់ស្រុកទាំងអស់ ហើយវាមានសក្តានុពលក្នុងការធ្វើឱ្យប្រសើរឡើងដល់ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានដែលទ្រទ្រង់ដោយការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមនៅតាមតំបន់ជនបទ។ នៅពេលដែលចាប់ផ្តើមអនុវត្ត NREGS លោកនាយក រដ្ឋមន្ត្រីបានមានប្រសាសន៍ថា "យើងសម្លឹងទៅចាប់យកកម្មវិធីនេះ គឺដើម្បីបង្កើតនូវទ្រព្យសម្បត្តិដ៏បិតថេរមួយ និងពង្រឹង PRIs ដោយសារតែយ៉ាងហោចណាស់វាក៏ផ្តល់ការងារ ៥០% ដល់ Gram Panchayats ដែរ (ក្រុមប្រឹក្សាភូមិ)។ គេត្រូវអនុវត្តនូវការឃ្លាំមើលការងារចំនួន ៣គឺ : ការចំណាយត្រូវតែ ស្របទៅនឹងលទ្ធផលដែលទទួលបាន ត្រូវបង្កើនទ្រព្យសម្បត្តិប្រកបដោយភាពច្នៃប្រឌិត និងត្រូវធានាចំពោះការប្តេជ្ញាចិត្តពិត" ។

ស្រុក ឃុំ និង ក្រុមប្រឹក្សាភូមិ គឺជាប្រធានអាជ្ញាធរសម្រាប់ការធ្វើគម្រោង និងការអនុវត្តនូវគម្រោងការនេះ។ យ៉ាងហោចណាស់ក៏មានការងារដែលផ្តល់កម្រៃ ៥០% ត្រូវបានគេផ្តល់ឱ្យ gram panchayat (GP) ដែរដែលក្នុងនេះ ២៥% សម្រាប់ថ្នាក់ឃុំ និង ២៥% ទៀតសម្រាប់ថ្នាក់ស្រុក។ NREGA បានផ្តល់សិទ្ធិអំណាចដល់សវនកម្មសង្គមក្នុងគោលបំណងធ្វើគម្រោងអនុវត្តនិងវាយតម្លៃទៅលើគម្រោង ដែលធានាភាពមានការងារធ្វើឱ្យកាន់តែមានការចូលរួមប្រកបដោយតម្លាភាព និងគណនេយ្យភាព (NREGA, ផ្នែកទី 17)។ គោលការណ៍របស់ NREGA ណែនាំនូវភាពដែលមិនអាចខ្វះបាននៃសវនកម្មសង្គម។ វាផ្តល់នូវបញ្ជីត្រួតពិនិត្យ និងធ្វើគម្រោងរចនាសម្ព័ន្ធសម្របសម្រួល ដែលតម្រូវឱ្យមានជាបឋមក្នុងចំណោមគណៈកម្មាធិការអង្កេត និងត្រួតពិនិត្យរបស់អ្នកភូមិ គឺជាកម្មសិទ្ធិរបស់ភូមិ/ ទីតាំងអនុវត្តការងារ។ Gram panchayats មិនត្រឹមតែទទួលខុសត្រូវក្នុងការសម្របសម្រួលដំណើរការសវនកម្ម សង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវធ្វើឱ្យ gram sabha (កិច្ចប្រជុំរបស់ភូមិ) ដឹងពីសារៈសំខាន់របស់វា និងកសាងសមត្ថភាពដើម្បីលើកឡើងនូវបញ្ហា។

ក្រោមច្បាប់របស់ Panchayati Raj Act នៅតាមបណ្តារដ្ឋទាំងអស់ដែលមាន gram sabha, ward sabha, palli sabha (គណៈកម្មាធិការភាពជាអ្នកជិតខាង) គឺជាស្ថាប័នបញ្ញត្តិក្នុងកាធ្វើគម្រោង និងត្រួតពិនិត្យសកម្មភាព

និងកម្មវិធី អភិវឌ្ឍ ។ Goa បានដាក់ស្នើធ្វើវិសោធនកម្មច្បាប់រដ្ឋធម្មនុញ្ញស្តីពីការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍ (Ward Development Council) ដើម្បីធ្វើគម្រោងសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅ Gram Panchayat ។ លើសពីនេះទៅទៀតវេទិកាសវនកម្មសង្គមក្នុង Rajasthan Gram Unnayan Samiti (គណៈកម្មាធិការអភិវឌ្ឍភូមិ) និងគណៈកម្មាធិការអ្នកទទួលផលនៅ West Bengal គណៈកម្មាធិការអង្កេតនៅ Tripura, Bihar, Goa, Himachal Pradesh និង Manipur ត្រូវបានគេ បង្កើតឡើងដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការធ្វើគម្រោង ការត្រួតពិនិត្យ និងតួនាទីគ្រប់គ្រង ។

ក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះ ការអនុវត្ត និង ការប្រកាសរបស់សវនកម្មសង្គមទទួលបាននូវភាពទូលំទូលាយ និងពហុនិយម ។ ដំបូងមានការអនុវត្ត ៣ប្រភេទនៅតាមតំបន់ផ្សេងៗក្នុងប្រទេស ។

មធ្យោបាយដំបូងគឺផ្តោតទៅលើក្របខ័ណ្ឌនីតិបញ្ញត្តិស្វ័យតតាមរយៈការបង្ហាញនូវការគាំទ្រយ៉ាងពេញទំហឹង (pro-active disclosure) នៅ gram sabha ។ ក្តារព្រឹត្តិប័ត្រព័ត៌មាននៅកន្លែងធ្វើការផ្តល់នូវព័ត៌មានទាក់ទងទៅនឹងពលកម្ម និងការចំណាយដែលចាប់ផ្តើមដំបូងនៅរដ្ឋ Kerala និងកំពុងត្រូវបានគេអនុវត្តនៅរដ្ឋដ៏ទៃជាច្រើនទៀត ។ រដ្ឋ Kerala មានដំណើរការគួរឱ្យកត់សម្គាល់ក្នុងការផ្សាយលម្អិតពីព័ត៌មានដែលទាក់ទងទៅនឹង NREGA នៅលើក្តារព្រឹត្តិប័ត្រព័ត៌មាន ។ ទាំងនេះ គឺវាភ្ជាប់ទៅនឹងការប្តេជ្ញាចិត្តមុនរបស់ពួកគេចំពោះដំណើរការសកម្មមុន ។ព័ត៌មាននេះជួយឱ្យប្រជាពលរដ្ឋចាប់អារម្មណ៍ទៅនឹងកម្មវិធីអភិវឌ្ឍ ។ មានរដ្ឋជាច្រើនកាលពីមុនក៏បានបញ្ជាក់ដែរថាក្នុងការជ្រើសរើសការទទួលបានផលប្រយោជន៍មានការកើនឡើងនូវការចូលរួមនៅ gram sabha ដែលបង្ហាញថានៅពេល ដែលបញ្ហារបស់ប្រជាជនក្នុងស្រុកត្រូវបានគេលើកយកមកពិភាក្សាប្រកបដោយតម្លាភាពប្រជាជនពិតជាចូលរួម ។

សៀវភៅណែនាំសវនកម្មសង្គមរបស់ Rajasthan ផ្តល់នូវមធ្យោបាយមួយជំហានម្តងៗ ដើម្បីធ្វើសវនកម្មសង្គមប្រកបដោយប្រសិទ្ធភាព ។ រដ្ឋាភិបាល Karnataka បានចេញបទបញ្ជាដើម្បីបង្កើតអាណត្តិសវនកម្មសង្គម ហើយក៏បានបញ្ចូលសមាជិកថ្មីដោយតែងតាំងមន្ត្រីរដ្ឋាភិបាលធ្វើជាបុគ្គលិកសវនកម្មក្នុងតំបន់នៅថ្នាក់ Gram Panchayat ។ ការធ្វើបែបនេះ ត្រូវបានគេរំពឹងថានឹងដំណើរការជាយន្តការត្រួតពិនិត្យចាំបាច់នៅក្នុងតំបន់ ដោយផ្តល់នូវការចំណាយហិរញ្ញវត្ថុដែលគួរឱ្យកត់សម្គាល់ដល់ Gram Panchayat ។ Kerala ក៏ធ្លាប់ត្រូវបានគេសាកល្បងអនុវត្ត និងពិសោធគោលការណ៍សវនកម្មនៅស្រុកផងដែរ គឺនៅស្រុក Wayanad និងស្រុក Palakkad ដែលក្នុងរយៈពេលខ្លីបន្ទាប់មកពង្រីកទៅដល់ស្រុក Idduk និងស្រុក Kozhikode ។

វិធានទីពីរគឺគំរូកិច្ចសហការណ៍គ្នារវាងស្ថាប័នក្នុងស្រុក និងអង្គការសង្គមស៊ីវិលដែលមានឥទ្ធិពលក្នុងតម្លៃនៃភាពជាដៃគូសម្រាប់កិច្ចព្រមព្រៀងរួមនិងលើកកម្ពស់គណនេយ្យភាព។ វិធាននេះត្រូវបានគេផ្តោតជាសំខាន់លើការបង្កើតនូវឱកាសសម្រាប់ការពិភាក្សា និងការវាយតម្លៃរួម។ ទោះជាយ៉ាងណាក៏ដោយវិធាននេះគឺគ្រាន់តែជាដំណាក់កាលចាប់ផ្តើមតែប៉ុណ្ណោះ។ អង្គការសង្គមស៊ីវិលនៅតាមបណ្តារដ្ឋជាច្រើនបានចុះមកសិក្សាដកស្រង់បទពិសោធន៍ពីតំបន់ Panchayats ហើយមន្ត្រីរដ្ឋាភិបាលបានអនុវត្តការធ្វើបែបបទធ្វើប័ណ្ណរបាយការណ៍ដោយមិនត្រឹមតែសម្រាប់ NREGS ទេ ប៉ុន្តែថែមទាំងសម្រាប់កម្មវិធីផ្តល់សេវាកម្មផ្សេងៗទៀតផងដែរ។

គំរូទីបីគឺពាក់ព័ន្ធទៅនឹងការប្រឆាំងអំពើពុករលួយ។ កត្តាដែលប្លែក ហើយដែលត្រូវត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ចំពោះគំរូនេះគឺការមិនចូលរួមពីភ្នាក់ងាររបស់រដ្ឋ និង PRIs។ វិធាននេះគឺពឹងផ្អែកទៅលើការប្រើប្រាស់ RTI ដើម្បីទទួលបាននូវកំណត់ត្រាសាធារណៈ។ វេទិកាបឋមគឺការជឹងព្វជាសាធារណៈ (Jan Sunvaai) ដែលត្រូវបានគេប្រើសម្រាប់សហគមន៍ដើម្បីចាត់វិធានការចំពោះបញ្ហាពុករលួយ។ វាបានបង្ហាញជាភស្តុតាងថាការផ្តើមគំនិតបែបនេះបានបង្ហាញផ្លូវសម្រាបផ្តល់អំណាចប្រជាពលរដ្ឋសាមញ្ញ ដើម្បីទទួលខុសត្រូវចំពោះសេវាកម្មផ្តល់សេវាកម្ម។ វាក៏បានបន្សល់នូវប្រតិកម្មភ្លាមៗ និងការមិនយល់ស្របពីអ្នកតំណាងក្នុងស្រុកដែលបានជ្រើសរើស និងរដ្ឋបាលរបស់រដ្ឋ។

គំរូទីមួយ (ការលាតត្រដាងជាមុន) បានបន្តបន្សល់នូវនិតិវិធីរដ្ឋបាលមួយ។ បុគ្គលដែលមានអំណាចមិនត្រឹមតែរៀបចំនូវរបៀបវិរៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតនូវ "កិច្ចព្រមព្រៀងបង្គាប់បញ្ជា" ដែលផ្ទុយទៅនឹង " កិច្ចព្រមព្រៀងដែលមានការព្រមព្រៀងគ្នា"។ នៅក្នុងគំរូនេះ ការចូលរួមរបស់សហគមន៍មានសភាពអន់ខ្សោយ ប្រជាពលរដ្ឋមិនយល់ពីព័ត៌មាន ហើយការសួរសំណួរជាសារធាណៈមិនត្រូវបានគេលើកទឹកចិត្តឡើយ។ ស្ថាប័នដែលប្រតិបត្តិសវនកម្មសង្គមមានការជំទាស់ផ្ទៃក្នុង ហើយដំណើរការគឺខ្វះការជឿជាក់ពីសាធារណៈជន។ gram panchayat sarpanches (មេភូមិ) នៅ Rajasthan ដែលគេឱ្យឈ្មោះថា sammelan (ការប្រមូលផ្តុំ) បានសម្រេចចិត្តមិនចូលរួមក្នុងសវនកម្មសង្គម និង Sarpanches នៅក្នុងស្រុក Banswada ក៏ជំទាស់ទៅនឹងសវនកម្មសង្គមដែរ (The Hindo, ១១ តុលា ២០០៧)។ នៅក្នុងកាលៈទេសៈបែបនេះ ក្រុមដែលត្រូវបានបដិសេធនេះមិនអាច ប្រមូលផ្តុំភាពខ្លាំងរបស់ខ្លួនដើម្បីលើកជាសំណួរមុន gram sabha ឡើយ។

សវនកម្មសង្គមទទួលរងឥទ្ធិពលពីនយោបាយដែលគ្រប់គ្រងដោយសមាជិកដែលមានអំណាច និងស្ថាប័នផ្សេងៗ។

ដើម្បីលើកកម្ពស់គណនេយ្យភាពសហគមន៍ ចាំបាច់ត្រូវបង្កើតយន្តការធម្មនុញ្ញដើម្បីធ្វើឱ្យប្រជាពលរដ្ឋសាមញ្ញមិនមានភាពភ័យខ្លាចក្នុងការចូលរួម ការពិនិត្យរបាយការណ៍ និងការលើកជាសំណួរ។ ជាទូទៅសវនកម្មសង្គមចាំបាច់ត្រូវមានការចូលរួមជាសាកល ដោយមានការពាក់ព័ន្ធពីទីភ្នាក់ងារនានាជាច្រើន និងប្រជាពលរដ្ឋគ្រប់ស្រទាប់ជាន់ថ្នាក់។ ជាឧទាហរណ៍នៅ Rajasthan គោលការណ៍សម្រាប់ NREGS បានបង្កើតនូវបទបញ្ញត្តិនៃវេទិកាសវនកម្មសង្គមដែលប្រតិបត្តិសវនកម្មសង្គម ហើយ gram sabha បានតែងតាំងប្រធានមួយរូប។ Sarpanch ឬ មន្ត្រីនានាផ្សេងៗទៀតមិនអាចដឹកនាំកិច្ចប្រជុំសវនកម្មសង្គមឡើយ។ បទបញ្ញត្តិផ្តល់អំណាចដល់សមាជិក gram sabha ដើម្បីត្រួតពិនិត្យទាំងស្រុងទៅលើដំណើរការសវនកម្មសង្គម។

នៅក្នុងសេចក្តីថ្លែងការស្តីពីសវនកម្មសង្គមនេះ អ្នកវិភាគ និងអ្នកអនុវត្តការងារអាជីពជាច្រើនគិតថា ឱកាសរបស់អ្នកទទួលផល ជាពិសេសករណីរបស់ NREGS ឱកាសរបស់ពលករត្រូវផ្តល់អំណាចដើម្បីរៀបចំសវនកម្មសង្គម។ បទបញ្ញត្តិនីតិកម្ម និងគោលការណ៍ណែនាំគោលនយោបាយត្រូវការវិវឌ្ឍឱ្យហួសពីសកម្មភាពជានិមិត្តរូប។ វាជាការចាំបាច់ដែលត្រូវកសាងសមត្ថភាពនៅគ្រប់ជាន់ថ្នាក់ទាំងអស់ និងគ្រប់បណ្តាស័ក្តិ ដើម្បីលុបបំបាត់ភាពភ័យខ្លាចនៅក្នុងសវនកម្មសង្គម។ សហគមន៍ដែលកំពុងមានចម្ងល់ និងកំពុងស្វែងរកការអធិប្បាយបញ្ជាក់ គឺជាបទពិសោធន៍ដែលមានការប្រែប្រួលមួយ។ សវនកម្មសង្គម គឺផ្តល់សំឡេងដល់ប្រជាជនក្រីក្រ។

គោលបំណងទាំងមូលនៃសវនកម្មសង្គមគឺចាប់អ្នកប្រព្រឹត្តអំពើពុករលួយ។ ទោះជាយ៉ាងនេះក្តី ដើម្បីសម្រេចដំណាក់កាលនេះឱ្យបាន គឺត្រូវឱ្យមានការបង្កើតយន្តការជាជំហានៗ ដើម្បីឱ្យអ្នកក្រ អ្នកទទួលផល ពលករ គិតថាពួកគាត់មានអំណាចនៅក្នុងការបញ្ចេញនូវសំឡេងរបស់ពួកគាត់នៅក្នុងមជ្ឈដ្ឋានដែលសេរី និងគ្មានការភ័យខ្លាច។ គឺមានការចាំបាច់ក្នុងការជំនះទៅនឹងមជ្ឈដ្ឋានដែលមានឧបសគ្គចំពោះសវនកម្មសង្គម។ ជំហានទី១ គឺធានាភាពស្របច្បាប់តាមរយៈក្របខ័ណ្ឌនីតិកម្ម។ បន្ថែមពីលើនេះទៀត ត្រូវការបង្កើតយន្តការជំនួយសម្រាប់ការចូលរួមរបស់អ្នកភូមិនៅក្នុងការអនុវត្តគម្រោង។ រដ្ឋបាលរបស់ Gujarat កំពុងរៀបចំការបណ្តុះបណ្តាលមន្ត្រីនៅតាមស្រុក និងអ្នកតំណាងរបស់ PRI តាមរយៈការជួបគ្នាផ្ទាល់ និង SATCOM ដើម្បីបង្កើតមជ្ឈដ្ឋានដែលប្រកបដោយលទ្ធភាពក្នុងការយល់ដឹងពីបទបញ្ញត្តិដ៏ច្រើនរបស់ NREGS។

ដំណើការសវនកម្មសង្គមនៅក្នុងផ្នត់គំនិតពិតប្រាកដរបស់ខ្លួនគឺមានដែនកំណត់មួយ។ ទោះបីជាយ៉ាងនេះក្តី បទពិសោធន៍ដែលមានដែនកំណត់នោះ បង្ហាញថា វាបានដឹងការពិតដ៏ស៊ីជម្រៅរបស់ពលករ នៅក្នុងការចូលរួមការលើកឡើងនូវបំណងប្រាថ្នារបស់ពួកគេ ហើយនិងប្រាក់ចំណូលឋិតថេរដែលអាចផ្គត់ផ្គង់ជីវភាពបាន។ ដំណើរការទាំងឡាយបានបង្កលទ្ធភាពដល់ពលករ ដើម្បីពិភាក្សាអំពីការបង្កើតបុគ្គលភាពនៅក្នុងការងារដ៏សមស្របមួយដែល

អាចបង្កើតមូលធនដែលយូរអង្វែង និងប្រកបដោយចីរភាព ភាពរអាក់រអួលនៅក្នុងដំណើរការទូទាត់។ល។ K. S. Gopal of CEC, Hyderabad ដែលធ្វើការយ៉ាងជិតស្និទ្ធពលករ NREGA នៅក្នុងស្រុក Anantpur នៅក្នុង សៀវភៅព្រឹត្តិបត្រព័ត៌មានពីរក្បាលដែលបានបោះពុម្ពផ្សាយនៅពេលថ្មីៗនេះ ដែលមានចំណងជើងថា 'Capturing Imagination of Stakeholder' និង 'Making NREGA Succeed' បានលើកឡើងថា ប្រសិនបើ បទពិសោធន៍របស់ពលករត្រូវបានយកមកពិចារណាអន្តរាគមន៍តាមរបៀបថ្មីជាច្រើនអាចត្រូវបានបង្កើតឡើង។ មានការចាំបាច់ដែលត្រូវធ្វើការផ្លាស់ប្តូរពីការបោះបង់ NREGS' ទៅជាធ្វើវិនិយោគ NREGS ដើម្បីការប្រែក្លាយវិញ។

សវនកម្មសង្គមអាចធ្វើឱ្យមានការត្រួតពិនិត្យពិតប្រាកដទៅលើបញ្ហា និងទស្សនៈជាច្រើន។ វាអាចពិនិត្យមើលភាពសមស្របរបស់ការងារ ផលប៉ះពាល់មិនល្អទៅលើបរិស្ថាន ការប្រើប្រាស់ និងការបញ្ចូលរបៀបអនុវត្តថ្មីនៅក្នុងឧបករណ៍ និងការអនុវត្តដែលធ្វើឱ្យការងារប្រើកម្លាំងពលកម្មមានផាសុខភាព ព្រមទាំងការបង្កើនប្រាក់ចំណូល។ វាក៏អាចពង្រីកការយល់ដឹងអំពីការទូទាត់ប្រាក់តាមធនាគារ និងការិយាល័យប្រៃសណីយ៍ផងដែរ ដើម្បីបញ្ឈប់អំពើពុករលួយ។ ម្យ៉ាងវិញទៀត សវនកម្មសង្គមអាចបង្កើតនូវទស្សនៈថ្មីជាច្រើន ដើម្បីអនុវត្តពាក្យសង្កេតតាមដានបីឃ្លា (Three watch words) ដែលធ្វើឡើងដោយនាយករដ្ឋមន្ត្រីទៅលើការបង្កើត NREGS។ តារាងការងារដែលបានលើកឡើងនៅខាងក្រោមនេះ អាចត្រូវបានត្រួតពិនិត្យ និងធ្វើការនៅក្នុងសវកម្មសង្គម (១) ការចុះបញ្ជី (២) ការចេញប័ណ្ណការងារ (៣) ការខ្វះខាតពេលវេលា និងភាពលំបាកនៅក្នុងការចេញប័ណ្ណការងារ (៤) កម្រិតនៃការស្វែងយល់ពី បទបញ្ញត្តិផ្សេងៗរបស់ NREGA (៥) ពង្រីកវិសាលភាពនៃការយល់ដឹងអំពីការដាក់ពាក្យរកការងារធ្វើ (៦) តារាងអត្រា (៧) Gram Sabha សម្រាប់ការបង្កើត និងការឯកភាពការងារផ្ទាល់ខ្លួន (៨) ឧបករណ៍ដែលអាចរកបាននៅកន្លែងធ្វើការ (៩) ការទូទាត់ប្រាក់កម្រៃដែលសមស្រប និងទាន់ពេលវេលា (១០) ការជំរុញ និងការបញ្ចូលរបៀបថ្មីនៅក្នុងការជ្រើសរើសការងារ ការអនុវត្ត និងឧបករណ៍។ ដើម្បីធ្វើឱ្យ NREGS បានទទួលជោគជ័យ ត្រូវការលុបបំបាត់ការភ័យខ្លាចនៅក្នុងសវនកម្មសង្គម ហើយដាក់ដំណើរការនៅក្នុងដៃរបស់ពលករដើម្បីកសាងអនាគតនៅជនបទប្រទេសឥណ្ឌា។

សវនកម្មសង្គមដែលបានអនុវត្តទៅតាមស្មារតីពិតអាចផ្តួចផ្តើមនូវការចូលរួម ការសន្ទនា និងការត្រួតពិនិត្យជាសាធារណៈ។ វាអាចជួយពិនិត្យមើលទំនាក់ទំនងនៃគោលដៅ និងដំណើរការ។ វាអាចធានាថា ទំនាក់ទំនង និងផលកម្រៃនៃការចំណាយទៅលើក្រុមគោលដៅ។ ការយល់ច្បាស់អំពីចលនាសវនកម្មសង្គម ត្រូវការឱ្យបង្កើតនូវការត្រួតពិនិត្យឡើងវិញនូវគោលនយោបាយណែនាំ និងការអនុវត្ត។ សវនកម្មសង្គម នៅពេលតែមួយ អាចបម្រើ

ដល់គោលបំណងនៃសវនកម្ម និងវិធានការគណនេយ្យភាពជាមួយប្រជាជនដែលស្ថិតនៅក្នុងកំណែទម្រង់អភិបាលកិច្ច ។

**ដំណាក់កាលទាំង១០ របស់សវនកម្មសង្គម NREGS :**

1. បង្កើតកិច្ចព្រមព្រៀងដើម្បីផ្តួចផ្តើមបង្កើតសវនកម្មសង្គមនៅក្នុងរដ្ឋធម្មនុញ្ញជាមួយនិងរដ្ឋបាលស្រុក Panchayats អង្គការ NGOs នៅក្នុងតំបន់ ។
2. វគ្គបណ្តុះបណ្តាលតម្រង់ទិសស្តីអំពីដំណើរសវនកម្មសង្គមជាមួយនឹងវេទិកាសវនកម្មសង្គម/គណៈកម្មាធិការអង្កេត និងត្រួតពិនិត្យរបស់ភូមិ ភ្នាក់ងាររដ្ឋបាល Panchayat មន្ត្រីរដ្ឋាភិបាល អង្គការ NGOs ... ។
3. កំណត់ពេលវេលាសវនកម្មសង្គម ។ (រយៈពេល ៦ខែគឺជារយៈពេលដ៏សមស្របសម្រាប់សវនកម្មសង្គម ។ ប្រសិនបើរយៈពេលលើសពី ៦ខែប្រជាពលរដ្ឋមិនអាចប្រមូលព័ត៌មាន ទទួលព័ត៌មាន និងបទពិសោធន៏បានឡើយ) ។.
4. ផ្តួចផ្តើមបង្កើតនូវសវនកម្មជាមួយនឹងការចូលរួមពីគណៈកម្មាធិការអង្កេត និងត្រួតពិនិត្យរបស់ភូមិ និងភ្នាក់ងារអនុវត្តដូចជា PRIs នាយកដ្ឋានព្រៃឈើ... ។

4.1 ប្រមូលបញ្ជីឈ្មោះសរុប និងបញ្ជីឈ្មោះផ្សេងៗទៀត ។

4.2 ប្រើប្រាស់សំណាកបញ្ជីឈ្មោះដោយជម្រើស ១០% ។

4.3 វិភាគទៅលើទិន្នន័យទ្រង់ទ្រាយបង្កើតជាមុន ។

4.4 បែងចែកទិន្នន័យជាមួយនឹងការចុះទៅដល់ផ្ទះសម្បែង និងធ្វើទស្សនៈកិច្ចដល់ទីកន្លែង ។

4.5 បង្កើតនូវរបាយការណ៍ជាសេចក្តីព្រាងនិងធ្វើកិច្ចពិភាក្សានៅក្នុងកិច្ចប្រជុំដ៏តូចមួយនៅ falia/ថ្នាក់សង្កាត់ ។

4.6 រៀបចំបង្កើត gram sabha ដែលការជូនដំណឹងនោះត្រូវតែធ្វើទៅតាមច្បាប់ gram sabha ថ្នាក់រដ្ឋ ។

4.7 រាល់ភ្នាក់ងារប្រតិបត្តិទាំងអស់ត្រូវមានវត្តមាននៅ gram sabha ។

4.8 កត់ត្រានូវដំណើរការរបស់ gram sabha ។

4.9 ដោះស្រាយបញ្ហាដែលកើតឡើងនៅ gram sabha ឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន ។

4.10 បញ្ជូនពាក្យបណ្តឹងទៅកាន់អាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការដោះស្រាយ ។